# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៦ ខែមករា លេខ ១

ព.ស. ២៤៩៦ – គ.ស. ១៩៥៤

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា　　　　បញ្ជីរឿង　　　　ទំព័រ


— បឋានកថា .................. ព្រះទេពមុនី យូរ- ប៊ុណ្ណ ..... ៣

— មនុស្សយើងមិនផុតពីទុក្ខ .......... លោកប៊ូ - ប៉ូ ............ ១៤


ផ្នែកអក្សរសាស្ត្រ


— ភាតរភាពខាងពុទ្ធសាសនា ......... លោក ប៊ូ - ប៉ូ ............ ១៩

— ព្រះភគោភាទ .................. អ្នកស្រី ឆាំ - ជុំ ............ ២៤

— ការបណ្ដុះនិស្ស័យ (តមក) ......... ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៊ម ... ៣០

— រឿងសាមកុក (តមក) ........... ឧកញ៉ា នូ - កន ........... ៣៦

— នាលះនឹងទមយន្តី .............. អ្នក ស្រី ស្រ៊ិន សារីយ៉ាន់ ...... ៤៦

— រឿងចិញ្ចៀនទិព្វ (តចប់) .......... អ្នកស្រី ស្រ៊ិន សារីយ៉ាន់ ..... ៥១

— រឿងប៉ូលនឹងវីរ៍ស៊ីនី (តចប់) ....... លោក ផេង - ផ្ទើវ ......... ៦៦


កំណត់នៃប្រវត្តិការណ៍


— បុណ្យឈាបនកិច្ចសពឧបាសិកា រុត ... ព្រះគ្រូសង្ឃសត្ថា ប៉ុណ្យ - សម្ផាន ៧៨



មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃផ្សារ ២០០ រៀល

បធានកថា

ព្រះទេពមុនី យូរ-ប៉ុណ្ណ ក្រុមជំនុំព្រះត្រៃបិដក

រៀបរៀង

---

# នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការចំពោះព្រះអរហំសម្មាសម្ពុទ្ធមានជោគព្រះអង្គនោះ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយសេចក្ដីគោរព) ។

វេលានេះ នឹងសំដែងអំពីបធានកថា តបស្នងនូវសទ្ធានៃសាធុជន អ្នកជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ដូចតទៅនេះ ៖

បធានៈ ប្រែថា "សេចក្ដីព្យាយាម" គឺព្យាយាមញុំាងសាធារណប្រយោជន៍ទាំងបច្ចុប្បន្នទាំងបរលោក ឬញុំាងប្រយោជន៍ផ្ទាល់ខ្លួនឲ្យកើតឲ្យមានឡើង ហៅថា បធានៈ ។

បធានៈ នោះមាន ៤ យ៉ាងគឺ

១— សំវរប្បធានៈ ព្យាយាមប្រយ័ត្នមិនឲ្យបាបកើតឡើង

២— បហានប្បធានៈ ព្យាយាមលះបាបដែលកើតឡើងហើយ

៣— ភាវនាបធានៈ ព្យាយាមធ្វើកុសលឲ្យកើតមានឡើង

៤— អនុរក្ខនាបធាន: ព្យាយាមរក្សាកុសលដែលកើតឡើងហើយ ។

បធាន: ទាំង ៤ យ៉ាងនេះ បើសំដែងរួបរួមដោយកិច្ចមាន ២ យ៉ាងគឺ:

១— បហានកិច្ច កិច្ចដែលត្រូវលះបង់

២— ភាវនាកិច្ច កិច្ចដែលត្រូវចំរើន ។

អធិប្បាយ: បហានកិច្ច "កិច្ចដែលត្រូវលះបង់" នោះ គឺលះបង់នូវអំពើបាប; ពាក្យថាបាប សំដៅយកអំពើអាក្រក់ ៣ យ៉ាងគឺ កាយទុច្ចរិត ៣ វចីទុច្ចរិត ៤ មនោទុច្ចរិត ៣ ។ កម្មដំណាមកទាំង ៣ នេះ សុទ្ធតែជាបាបទាំងអស់ ។ ក្នុងបាលីមានសំដែងអំពីបាប ៣ ពួកនេះ ច្រើនជាងចំណែកដទៃៗ ព្រោះបាបអម្បាលនេះ ជាប្រធានរបស់បាបទាំងពួង; សូម្បីបាបដទៃៗ ក៏រួមចូលក្នុងបាប ៣ ពួកនេះដែរ ។

បណ្ដាបាបទាំងប៉ុន្មានដែលបានពោលមកនេះ ឥតមានចំណែកណាមួយដែលជារបស់គួរធ្វើ គួរប្រព្រឹត្តសោះឡើយ ។ សមដូចព្រះពុទ្ធដីកានៃព្រះភគវត្តមុខដែលត្រាស់នឹងព្រះអានន្ទថា "ម្នាលអានន្ទ! តថាគតហៅ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ថាជាកិច្ចដែលបុគ្គលមិនគួរធ្វើដោយដាច់ខាត" ។ កាលបើបុគ្គលណាមួយដែលធ្វើអករណីយកិច្ចនោះដោយ កាយ វាចា ចិត្ត ហើយ ត្រូវដឹងខ្លួនចុះ ជាមុខជានឹងមានទោសពុំខាន ។

ឯទោសប្រព្រឹត្តទុច្ចរិត នោះ មាន ៥ យ៉ាងគឺ

១– សូម្បីខ្លួនឯងក៏តិះដៀលខ្លួនឯងដែរ

២– លោកអ្នកចេះដឹងរិះគន់មើល រមែងតិះដៀលបាន

៣– កេរ្តិ៍ឈ្មោះអាក្រក់ រមែងល្បីខ្ចរខ្ចាយទៅសព្វទិស

៤– វង្វេងភ្លេចស្មារតីក្នុងពេលដែលទៀបស្លាប់

៥– ខាងមុខអំពីទំលាយខន្ធទៅ រមែងទៅកើតក្នុងទុគ្គតិ ។

បុគ្គលណាធ្វើបាបដូចបានពោលមកនេះ រមែងក្តៅក្រហាយក្នុងលោកទាំងពីរ គឺក្នុងលោកនេះ កើតទុក្ខក្តៅក្រហាយដោយគិតថា អាត្មាអញបានធ្វើបាបដូច្នោះៗ ។ លុះច្យុតចាកលោកនេះទៅហើយ រឹងតែក្តៅក្រហាយជាងនេះទៅទៀត ។

ព្រោះហេតុនោះ បានជាព្រះអរហំសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា បាបនេះជាអំពើមិនគួរធ្វើ មិនគួរប្រព្រឹត្តឡើយ ។

**ភាវនាកិច្ច** "កិច្ចដែលគួរចំរើន" នោះ គឺកម្មដែលកំចាត់បង់នូវសេចក្តីអាក្រក់ ហៅថាកុសល. ការដែលព្យាយាមធ្វើកុសលឲ្យកើតឲ្យមានឡើងហៅថា បំពេញកុសលឲ្យបរិបូណ៌ ។ កុសលនោះ បើសំដែងដោយបុគ្គល បានដល់ **អលោភោ** ការមិនចំពាក់ចិត្តនឹងទ្រព្យសម្បត្តិ គឺមិនចង់បាននូវទ្រព្យសម្បត្តិរបស់អ្នកដទៃ មិនលួចលាក់ឆក់ដណ្តើមបំបាត់ប្រវញ្ចន៍ សង្កត់សង្កិនរបដាន់យកទ្រព្យសម្បត្តិរបស់គេ

ដោយឥតមេត្តា, អទោសោ មិនប្រទុស្ត គឺមិនខឹងមិនរករឿងរកហេតុអ្នកដទៃឲ្យគេដល់នូវសេចក្ដីវិនាស, អមោហោ មិនវង្វេងភ្លេចស្មារតី ដោយអ្នកដទៃគេគម្រាម កំហែង បំភាន់គំនិតជាដើមឡើយ ។

មួយទៀត កុសលនេះបើសំដែងដោយទីកើតមាន ១០ ប្រការ គឺ

១ — ការឲ្យនូវវត្ថុដ៏គួរដល់បុគ្គលដែលគួរឲ្យដោយសេចក្ដីសង្គ្រោះ ឬឲ្យជាគុណមានឲ្យដល់មនុស្សកំសត់ទុគ៌ត ឬឲ្យជាដល់អ្នកមានសីលធម៌ ឪមាតាបិតាជាដើម ហៅថា ទានៈ ។

២ — ការវៀរចាកអំពើអាក្រក់ដែលកើតអំពី កាយ វាចា មាន វៀរបញ្ចវេរជាដើម ហៅថា សីលៈ ។

៣ — ការធ្វើចិត្តឲ្យស្ងប់រម្ងាប់ចាកអកុសលធម៌ មាននីវរណធម៌ ជាដើម ដោយសមថវិធីនឹងវិបស្សនាវិធី ហៅថា ភាវនា ។

៤ — ការទំរុះទំរេមអស្មិមានះដែលកើតមានក្នុងចិត្ត ដោយសេចក្ដីកោតក្រែង ចំពោះបុគ្គលដែលគួរកោតក្រែង គឺជនដែលចំរើនដោយជាតិ ដោយវ័យ ដោយគុណ ហៅថា អបចាយនៈ ។

៥ — ការជួយខ្វល់ខ្វាយក្នុងកិច្ចការកុសល ហៅថា វេយ្យាវច្ចៈ ។

៦ — ការឲ្យនូវចំណែកបុណ្យដែលខ្លួនបានធ្វើហើយ ដល់អ្នកដទៃ ដោយមេត្រីចិត្ត ដើម្បីឲ្យគេត្រេកអរតាម ហៅថា បត្តិទានៈ ។

៧ - ការអនុមោទនាត្រេកអរតាមនូវសេចក្ដីល្អរបស់អ្នកដទៃដែលគេបានធ្វើហើយ ដោយចិត្តដែលប្រាសចាកសេចក្ដីច្រណែនឈ្នានីស ហៅថា បត្តានុមោទនា ។

៨ - ការណែនាំបង្ហាត់បង្រៀនប្រៀនប្រដៅអ្នកដទៃ ឲ្យចេះចំណេះវិជ្ជាដែលឥតទោស ឬពន្យល់ប្រាប់គន្លងផ្លូវលោកផ្លូវធម៌ ឲ្យស្គាល់កិច្ចគួរធ្វើ និងមិនគួរធ្វើ ដែលប្រព្រឹត្តទៅដើម្បីសេចក្ដីសុខ-ចំរើនក្នុងបច្ចុប្បន្ននេះ រហូតដល់សម្បត្តិសួគ៌ សម្បត្តិព្រះនិព្វានជាទីបំផុត ហៅថា ធម្មទេសនា ។

៩ - ការតាំងចិត្តស្ដាប់ធម៌ ស្ដាប់ពាក្យទូន្មាន ពាក្យប្រៀនប្រដៅ ដោយប្រុងឲ្យចេះចាំស្ទាត់ធ្វើកើត និយាយបាន ហៅថា ធម្មស្សវនៈ ។

១០- ការធ្វើទិដ្ឋិ គឺសេចក្ដីយល់ឃើញរបស់ខ្លួនឲ្យត្រូវតាមគន្លងធម៌ដែលពិតមែន ហៅថា ទិដ្ឋុជុកម្មៈ ។

អំពើទាំង ១០ ប្រការនេះ ហៅថាបុញ្ញកិរិយាវត្ថុ គឺជាទីកន្លែងសម្រាប់កើតបុណ្យ ។ បុគ្គលណាបានធ្វើកុសលដូចបានពោលមកនេះ, បុគ្គលនោះរមែងបាននូវអានិសង្ស ៤ យ៉ាង គឺ:

១- សូម្បីខ្លួនឯងក៏សរសើរខ្លួនឯង

២- អ្នកប្រាជ្ញទាំងឡាយលោកពិចារណាឃើញតាមការពិតហើយ លោករមែងសរសើរ

៣– មានកិត្តិស័ព្ទពីរោះល្បីខ្ចរខ្ចាយទៅសព្វទិស

៤– មិនវង្វេងភ្លេចស្មារតីក្នុងពេលធ្វើមរណកាល

៥– រមែងទៅកើតក្នុងសុគតិ ។

បហានកិច្ច និង ភាវនាកិច្ចដែលបានសំដែងមកនេះ ជាដំណើរខាងផ្លូវធម៌ បើជាខាងផ្លូវលោកវិញ សំដៅយកការលះបង់នូវឫកពា មារយាទអាក្រក់ ក្រអឺតក្រអោង កោងកាច ខ្ជិលច្រអូស ដើរលេងស៊ីផឹក ចាយវាយទ្រព្យសម្បត្តិឥតប្រយោជន៍ ឥតសណ្ដាប់ធ្នាប់ ធ្វើចោរកម្មលួចប្លន់គេដណ្ដើម រំលោភសង្កត់សង្កិនយកធនធានអ្នកដទៃជាដើម ។ អំពើអស់នេះ សុទ្ធតែជាអំពើនាំឲ្យថោកទាបឲ្យទន់ខ្សោយឲ្យអាប់រស្មីដល់ខ្លួនឯង និងប្រទេសជាតិ មាតុភូមិ ជាអំពើនាំឲ្យលោកតិះដៀល; បុគ្គលអ្នកស្រឡាញ់សេចក្ដីល្អគួរលះបង់ចោល ។

ព្រោះហេតុនោះ យើងកើតមកជាមនុស្សម្នាក់ៗ ក្នុងលោកសន្និវាសនេះ មានអវយវៈគ្រប់គ្រាន់ មិនវិកលវិការៈ ដោយកាយគនៈណាមួយ គួរតែមានព្យាយាមបំពេញកិច្ចរបស់ខ្លួនឲ្យគ្រប់គ្រាន់ កុំពឹងផ្អែកទៅលើរូបបុគ្គលណាមួយឲ្យគេចិញ្ចឹមខ្លួននោះ មិនបានសម្រេចប្រយោជន៍ទេ, ព្រោះរូបនីមួយៗសុទ្ធតែមានសេចក្ដីសុខទុក្ខជាប់ទាក់ទងដោយរាងកាយ, ឬក៏មានរាងកាយជាទីអាស្រ័យនៅនៃសេចក្ដីសុខទុក្ខ ដូចជាគេហដ្ឋានជាទីអាស្រ័យនៅនៃមនុស្ស. ជីវិតសោតទៀតដែលនឹងតាំង

នៅបាន ក៏ព្រោះអាស្រ័យរាងកាយ ការគ្រប់គ្រងចិញ្ចឹមរាងកាយឲ្យបានធាត់ធំមាំមួនខ្លាំងពូកែទៅបាន ក៏ព្រោះអាស្រ័យសេចក្ដីព្យាយាមស្វែងរកអាហារ, កាលបើប្រាសចាកអាហារហើយ សត្វគ្រប់រូបដែលចំរើនធាត់ទៅក៏ឈប់ចំរើន ទាំងជីវិតសោតទៀត ក៏តាំងនៅបានដោយកម្រ ។ អាហារនេះជារបស់សំខាន់បំផុត សម្រាប់បម្រុងជីវិតឲ្យប្រព្រឹត្តទៅ, សមដូចបាលីថា សព្វេសត្តា អាហារដ្ឋិតិកា "ពួកសត្វពាល់រូបដែលមានជីវិតរស់នៅបាន ក៏ព្រោះអាហារ" ។ វត្ថុឯទៀត ។ ក្រៅពីអាហារនោះមានច្រើន ដូចយ៉ាងលំនៅជាទីជ្រកកោនសំពត់សម្រាប់ស្លៀកដណ្ដប់ ថ្នាំសម្រាប់កែរោគក្នុងពេលដែលត្រូវការប៉ុណ្ណេះជាដើម, វត្ថុទាំងអម្បាលនេះ សុទ្ធតែជារបស់ជួយឧបត្ថម្ភទប់ទល់ជីវិតទាំងអស់, បើប្រាសចាករបស់ណាមួយហើយ ជីវិតរមែងតាំងនៅបានដោយលំបាក ។

សូមទាញរឿងមហាជនកមកសំដែងក្នុងទីនេះ ដើម្បីឲ្យឃើញអានិសង្សនៃសេចក្ដីព្យាយាម ។

ព្រះពោធិសត្វព្រះនាម មហាជនក កាលលោមាតាចុះសំពៅទៅជួញជាមួយនឹងពួកឈ្មួញ, លុះដល់កណ្ដាលមហាសមុទ្រ សំពៅក៏ធ្លុះធ្លាយទៅដោយត្រូវខ្យល់ព្យុះខ្លាំង, ពួកឈ្មួញទាំងអស់ក៏ស្លាប់អស់ទៅ ។ ចំណែកខាងព្រះពោធិសត្វ មិនភ័យគិតតក់ស្លុតនឹងសេចក្ដីស្លាប់ឡើយ,

លោកនឹកដល់គុណមាតាបិតា និង គុណសីលដែលធ្លាប់បានប្រព្រឹត្តមក ហើយក៏លោតចេញអំពីសំពៅប្រឹងហែលសំដៅទៅកោះត្រើយម្ខាង អស់ចំនួន ៧ ថ្ងៃ, លុះដល់ថ្ងៃឧបោសថ លោករក្សានូវឧបោសថសីលតាំងកំពុងព្យាយាមហែលក្នុងមហាសមុទ្រ ។

ពេលនោះ មានទេពធីតា ១ អង្គឈ្មោះ មណិមេខលា នៅរក្សាមហាសមុទ្រ បានឃើញព្រះពោធិសត្វប្រឹងព្យាយាមហែលមិនមានឈប់យ៉ាងនេះ ក៏ស្រែកសួរថា:

"អ្នកណានេះ កាលបើមិនឃើញនូវកោះត្រើយសោះ ម្ដេចក៏ខំប្រឹងហែលក្នុងកណ្ដាលមហាសមុទ្រ តើអ្នកដឹងនូវប្រយោជន៍ដូចម្ដេច បានជាខំប្រឹងព្យាយាមហែលម្ល៉េះ?" ។

ព្រះជនកពោធិសត្វតបថា:

"ម្នាលទេវតា! ខ្ញុំពិចារណានូវវត្តនៃសត្វលោក និងអានិសង្សនៃសេចក្ដីព្យាយាម ព្រោះហេតុដូច្នោះ ខ្ញុំបើទុកជាមិនឃើញនូវកោះត្រើយក៏ដោយចុះ ក៏នៅតែប្រឹងព្យាយាមហែលក្នុងកណ្ដាលមហាសមុទ្រ (ទុកជាគម្រប់ដល់លោក ស្លាប់ពេលណា ឈប់ពេលនោះ មិនលះបង់នូវសេចក្ដីព្យាយាមទេ)" ។

នាងទេពធិតាពោលថា:

“ត្រើយមហាសមុទ្រជ្រៅកប្រមាណមិនបាន មិនប្រាកដដល់អ្នកណា ការព្យាយាមតាមកម្លាំងបុរស ក៏ជាការឥតអំពើដល់អ្នកនោះ អ្នកមិនដល់ត្រើយទេមុខជានឹងស្លាប់ ក្នុងកណ្តាលមហាសមុទ្រនេះពុំខានឡើយ” ។

ព្រះជនកតបថា:

“បុគ្គល (កំពុងព្យាយាម សូម្បីនឹងស្លាប់) ក៏បានឈ្មោះថាជាអ្នកមិនមានបំណុល គឺពួកញាតិពួកទេវតានឹងមាតាបិតាមិនបានតិះដៀលឡើយ បុគ្គលនោះ កាលបើបានធ្វើកិច្ចរបស់បុរសហើយ រមែងមិនក្តៅក្រហាយក្នុងពេលខាងក្រោយឡើយ” ។

នាងទេពធីតាពោលទៀតថា:

“ការងារណាមិនសម្រេចដោយសេចក្តីព្យាយាមទេ ការងារនោះទៅជារបស់ឥតផល មានតែសេចក្តីលំបាកជាកម្រៃ សេចក្តីស្លាប់រមែងសម្រេចដល់បុគ្គលណា បុគ្គលនោះនឹងមានប្រយោជន៍ដូចម្តេច ដោយការព្យាយាមនោះ” ។

ព្រះជនកតបថា

ម្នាលទេវតា ! បុគ្គលណាដឹងច្បាស់ថា ការងារមានទីបំផុតតែក្រពកមិនសម្រេចទេ ហើយលះបង់ចោលបែរជា

រក្សាជីវិតរបស់ខ្លួនទៅវិញ គឺបន្ថយនូវសេចក្ដីព្យាយាមពោលចេញ, បុគ្គលនោះគង់នឹងដឹងនូវផលនៃសេចក្ដីខ្ជិលច្រអូសនោះពុំខានឡើយ ។ ម្នាលទេវតា! បុគ្គលពួកខ្លះក្នុងលោកនេះកាលបើឃើញនូវផលនៃសេចក្ដីប្រាថ្នាហើយ រមែងប្រកបនូវការងារទាំងឡាយ ការងារទាំងនោះ ទោះបីសម្រេចក្ដីមិនសម្រេចក្ដី គួរតែចំប្រឹងព្យាយាមកុំខាន ។ ម្នាលទេវតា! ក្រែងអ្នកបានឃើញនូវផល នៃសេចក្ដីព្យាយាមជាក់ច្បាស់ដោយខ្លួនឯងដែរឬ? ជនទាំងឡាយឯទៀត ៗ លិចចុះក្នុងមហាសមុទ្រអស់ហើយ មកពីមិនមានសេចក្ដីព្យាយាម, ឯខ្ញុំតែម្នាក់ឯងទេដែលកំពុងហែលឆ្លងក្នុងមហាសមុទ្រ ទាំងបានឃើញអ្នកដែលស្ថិតនៅក្នុងទីជិតខ្ញុំ, ខ្ញុំនេះនឹងព្យាយាមតាមសមគួរដល់សេចក្ដីអង់អាច នឹងសមគួរដល់កម្លាំង, កាលបើខ្ញុំបានដល់ត្រើយនៃមហាសមុទ្រហើយ ខ្ញុំនឹងធ្វើនូវសេចក្ដីព្យាយាមដែលបុរសគប្បីធ្វើនោះ ឲ្យបានសម្រេចជាភិយ្យោភាព ។

លុះព្រះជនកពោធិសត្វពោលតែប៉ុណ្ណោះហើយ, ទេពធីតាក៏ស្ទុះទៅចាប់ដៃព្រះពោធិសត្វ ហើយទាញនាំយកទៅដាក់ដល់មិថិលានគរ, មិនយូរប៉ុន្មាន ព្រះពោធិសត្វក៏បានសោយរាជ្យក្នុងនគរនោះឯង ។

នាំរឿងក៏រមកប៉ុណ្ណេះដើម្បីឲ្យឃើញថា គុណសម្បត្តិនៃសេចក្តីព្យាយាមនេះ អាចឲ្យសម្រេចផលដល់បុគ្គលអ្នកមានសមត្ថភាព ។ បុគ្គលណា កាលបើមានសេចក្តីពេញចិត្តក្នុងការបំពេញកិច្ចរបស់ខ្លួន ហើយព្យាយាមបំពេញកិច្ចនោះ ក៏បានឈ្មោះថាប្រសើរជាទីបំផុត ។ ខ្លួនស្លាប់បាត់ទៅមែនតែកេរ្តិ៍ឈ្មោះនៅល្អ, ខ្លួនស្លាប់ទៅចុះ កុំឲ្យតែស្លាប់សេចក្តីព្យាយាម ។ សមដូចពុទ្ធភាសិតថា រូបំ ជិយ្យតិ មច្ចានំ នាមគោត្តំ ន ជិយ្យតិ រូបនៃសត្វទាំងឡាយរមែងស្លាប់ទៅ តែនាមនឹងគោត្រមិនស្លាប់ឡើយ ។ វិរិយេន ទុក្ខមច្ចេតិ គេចួនរួចសេចក្តីទុក្ខបានដោយសេចក្តីព្យាយាម ។

សំដែងអំពីបណ្ឌកថាចប់តែប៉ុណ្ណេះ, ។

សូមថ្វាយព្រះរាជកុសលចំពោះព្រះករុណាជាម្ចាស់ជីវិត សូមព្រះអង្គស្ថិតនៅក្នុងសិរីរាជសម្បត្តិអស់កាលដ៏យូរអង្វែងទៅ ! និងសូមឲ្យអស់លោកជាពលរដ្ឋធំ-តូច ព្រមទាំងពុទ្ធបរិស័ទទាំងឡាយក្នុងកម្ពុជរដ្ឋទាំងមូល បានសេចក្តីសុខចំរើនជានិយ្យាភាព ! ។

## មនុស្សយើងមិនផុតពីទុក្ខ(១)

### ឃុនបណ្ឌិតរ័ក្ស ប៊ុ-ប៉ូ រៀបរៀង

ជីវិតរបស់យើងទាំងឡាយដែលមិនសប្បាយរីករាយមិនស្រស់បស់នោះ ជាគ្រឿងចង្អុលបង្ហាញឲ្យដឹងថា "យើងកល់គ្នារងទុក្ខ" ។

ហេតុអ្វីបានជាយើងរងទុក្ខ?

ហេតុតែជីវិតរបស់យើងគ្មានឥស្សរភាព ។

ហេតុអ្វីបានជាជីវិតរបស់យើងគ្មានឥស្សរភាព?

ហេតុតែយើងជាប់ចំណង ១០ ប្រការ ។ ចំណងទាំង១០នោះ ចងគ្រៀកយើងជាប់ណាស់ ប៉ុន្តែក៏បន្ធាយឲ្យវែង បណ្តោយឲ្យយើងដើរត្រាច់ទៅបានតាមចំនើងចិត្ត តែក្នុងកំរិតវង្វង់ខ្សែដែលអនុញ្ញាតឲ្យយើងដើរប៉ុណ្ណោះ យើងនឹងដើរឲ្យហួសចេញក្រៅកំរិតខ្សែនោះទៅទៀតមិនបានទេ ប្រៀបដូចគោដែលគេចងនឹងស្នឹង ហើយចេះតែដើរក្រឡឹងជុំវិញស្នឹងដូច្នោះ ។

ចំណងទាំង១០នោះ គេវេញបញ្ចូលគ្នាជាខ្សែ១ចុង ចុងខ្សែម្ខាងចងក្រៀកខ្លួនយើងជាប់ ចុងខ្សែម្ខាងទៀតចងភ្ជាប់នឹងបង្គោលគ្រាក់មួយដ៏រឹងមាំមួនក្រៃលែង បើខ្សែនោះមិនទាន់សឹកដាច់ដរាបណា ជីវិត

---

១ អធិប្បាយអំពីធម៌ ១០ ជាគ្រឿងចងគ្រៀកមនុស្ស (សំយោជន៍ ១០) តាមច្បាប់ពុទ្ធសាសនា លេខ ម. ៤៣៤ ទំព័រ ៦០៦... ។

របស់យើងគឺគ្មានឥស្សរភាពដកបនោះជាដាច់ខាត ហេតុនេះហើយបានជាយើងមិនផុតពីទុក្ខ នេះជាពាក្យឆ្លើយតបនឹងប្រស្នាខាងដើម ។

ឯចំណងទាំង១០ប្រការនោះ វាចេះធ្វើឧបាយកលច្រើនយ៉ាងណាស់ វាចងយើងមិនឲ្យដឹងខ្លួនសោះ វាចេះធ្វើមាយាប្រលោមលួងលោមយើងឲ្យស្រុងចិត្តទៅតាមវា វាចេះធ្វើនែកក្ដៈយើងឲ្យមើលឃើញខ្លួនវាថាជាខ្មែរមានសង្ហារកើតកន់ជាំសុទ្ធតែត្បូងពេជ្រ យើងកើតចិត្តប្រតិព័ទ្ធស្នេហានឹងវាភ្លេចស្មារតីស្ទើបង្ហូរជីវិត លុះវាដឹងថាយើងភ្លេចខ្លួនហើយវាចង់ទាញយើងសន្សឹមៗ បន្តិចម្ដងៗ ឲ្យយើងធ្លាក់ខ្លួនទៅជាអ្នកទោសរបស់វា ឲ្យយើងទៅជាទាសភាពរបស់វា ហេតុនេះហើយបានជាជីវិតយើងគ្មានឥស្សរភាព ។

ចំណងទាំង១០ប្រការនោះ លោកអ្នកប្រាជ្ញខាងព្រះពុទ្ធសាសនាឲ្យឈ្មោះតាមភាសាបាលីថា សំយោជនៈ ប្រែថា "គ្រឿងចងមនុស្សសត្វ", មាន ១០ ប្រការគឺ ៖

បំណងទី១.— សេចក្ដីសំគាល់ខុសក្នុងរាងកាយទាំងមូលថា រូបរាងកាយនេះមានខ្លឹមសារ ទឹង សំគាល់ថាខ្លួនយើងមានអំណាចពេញលេញ អាចបង្គាប់បញ្ជារូបរាងកាយខ្លួនឯងឲ្យបានដូចចិត្តប្រាថ្នារបស់ខ្លួន ហើយប្រកាន់យករាងកាយទាំងមូលនោះថាជារបស់ខ្លួនជាដើម, តាមការពិត គំនិតដែលសំគាល់ដូច្នោះខុសស្រឡះទាំងអស់ ។

ខ្មែរនេះភាសាបាលីហៅថា សក្កាយទិដ្ឋិ "សេចក្ដីយល់ឃើញថាកងកាយជារបស់ខ្លួនយើង" ។

បំណងទី ២.— សេចក្ដីសង្ស័យថា ការវៀរខ្លួនឲ្យផុតពីការដេកលក់ គឺសេចក្ដីប្រមាទស្រវឹង, សេចក្ដីល្អប្រពៃដែលអាចផប់ជីវិតឲ្យស្រស់ថ្លាបាន, ការធ្វើដំណើរជីវិតត្រង់ទៅកាន់វិថីនៃសេចក្ដីបរិសុទ្ធ មានពិតមែនឬ ឬក៏គ្មានទេ ។ ខ្មែរនេះភាសាបាលីហៅថា វិចិកិច្ឆា "សេចក្ដីសង្ស័យ" ។

បំណងទី ៣.— ការមិនយល់ច្បាស់លាស់ ចូលចិត្តមិនត្រង់ មិនត្រូវគ្នានឹងការខំប្រឹងហាត់ពត់កាយវាចាឲ្យល្អបរិសុទ្ធ ទាំងមិនយល់ច្បាស់នូវសេចក្ដីរៀបរយដែលជាប់ទាក់ទងនឹងការហាត់ពត់កាយវាចា ត្រឡប់ជាវង្វេងយល់ខុសថា អំពើនោះៗ ជាអំពើឲ្យកើតបុណ្យខ្លាំងពូកែ ឲ្យមានសេចក្ដីសក្តិសិទ្ធិ ឯខ្លួននឹងស្អាតបរិសុទ្ធបាន ក៏ព្រោះតែសេចក្ដីសក្តិសិទ្ធិនោះឯងជាដើមចម ។ ខ្មែរនេះភាសាបាលីហៅថា សីលព្វតបរាមាសៈ "ការបបោសអង្អែលក្នុងសីលនឹងវត្ត" ។

បំណងទី ៤.— ជំរេកក្នុងអារម្មណ៍ជាទីស្រឡាញ់ ដែលមានកំដៅយ៉ាងខ្លាំងក្លា ព្រះពុទ្ធជាម្ចាស់ទ្រង់ហៅថា រាគគ្គិ "ភ្លើងរាគ" ។ ខ្មែរនេះភាសាបាលីហៅថា កាមរាគៈ "សេចក្ដីជំរេកក្នុងកាម" ។

បំណងទី៥.— សេចក្ដីថ្នាំងថ្នាក់នៃចិត្តក្នុងកាលមានសេចក្ដីក្រោធចូលមកគ្របសង្កត់ ៗ ពាក្យនេះភាសាបាលីហៅថា បដិឃៈ "សេចក្ដីទ្ទើមឬថ្នាំងថ្នាក់នៃចិត្ត" ៗ.

បំណងទី៦.— ចិតដែលជាប់ជំពាក់ក្នុងរូបធម៌ឬរូបភពដែលហួសទៅ តាលតែឃើញថារូបនោះជារបស់គួរត្រេកអរហើយក៏មានចិត្តជាប់ស្អិត ៗ ពាក្យនេះភាសាបាលីហៅថា រូបរាគ "ជំពេកក្នុងរូប" ៗ

បំណងទី៧.— ចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ដែលមិនមានរូបប្រាកដ គ្រាន់តែមានឈ្មោះជាគ្រឿងដឹង តាលតែឃើញថាអារម្មណ៍ទាំងនោះគួរត្រេកអរហើយជាប់ចិត្តស្អិតទៅ ៗ ពាក្យនេះភាសាបាលីហៅថា អរូបរាគ "ជំពេកក្នុងអរូប" ៗ

បំណងទី៨.— សេចក្ដីសំគាល់ខ្លួនឯងថា ខ្លួនយើងជាមនុស្សម្នាក់ដែរ ហើយយកខ្លួនទៅប្រៀបនឹងអ្នកដទៃ ជាហេតុឲ្យលើកកំពស់ខ្លួនថាខ្ពស់ជាងគេឬថាស្មើនឹងគេ ឬក៏ដាក់ខ្លួនថាថោកទាបជាងគេ ៗ ពាក្យនេះភាសាបាលីហៅថា មានៈ "សេចក្ដីប្រកាន់ខ្លួន" ៗ

បំណងទី៩.— សេចក្ដីអណ្ដែតអណ្ដូងនៃចិត្តទៅតាមអារម្មណ៍នោះៗ សេចក្ដីភាយមាយក្នុងអារម្មណ៍ ៗ ពាក្យនេះភាសាបាលីហៅថា ឧទ្ធច្ច "សេចក្ដីអណ្ដែតអណ្ដូង" ៗ

បំណងទី ១០.— សេចក្ដីមិនដឹងខ្លួន មិនដឹងប្រមាណ ការដឹងមិនទាន់ យល់មិនទាន់ ៗ ខ្សែនេះតាមភាសាបាលីហៅថា អវិជ្ជា "សេចក្ដីមិនដឹង" ។

មនុស្សយើងជាបុថុជ្ជនអ្នកក្រាស់ដោយកិលេស អាចនឹងកាត់ខ្សែចំណងទាំង ១០ ប្រការដាច់ដែរឬទេ?

អាចនឹងកាត់ដាច់បាន ប៉ុន្ដែមិនមែនកាត់តែម្ដងដាច់អស់ទាំង១០ទេ ត្រូវតែមានព្យាយាមកាត់ ១ សរសៃឬ ២ សរសៃម្ដង ដរាបដល់ដាច់អស់ទាំង១០ទើបយើងផុតពីទុក្ខ បើយើងកាត់ដាច់អស់ ៩ សរសៃហើយ នៅសល់តែ ១ សរសៃប៉ុណ្ណោះ ក៏យើងមិនទាន់ផុតពីទុក្ខដែរ ហេតុនេះយើងត្រូវតែព្យាយាមកាត់ឲ្យដាច់អស់គ្រប់ទាំង ១០ សរសៃ កុំឲ្យនៅសល់ ១ សរសៃឡើយ ។

ព្រះបរមគ្រូនៃយើងទ្រង់ត្រាស់ប្រាប់ថា “ មនុស្សនឹងផុតចាកទុក្ខបាន ព្រោះសេចក្ដីព្យាយាម ” គឺព្រះអង្គទ្រង់បង្គាប់ឲ្យយើងមានព្យាយាមខំកាត់កិលេសទាំងអស់ មានសំយោជន៍ ១០ ប្រការនេះជាដើម ទើបយើងនឹងផុតចាកទុក្ខ ក្លាយពីបុថុជ្ជនទៅជាព្រះអរិយៈបាន នេះជាពាក្យឆ្លើយតបនឹងប្រស្នាដែលតាំងទុកខាងដើម ។

ចប់